ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៦៣/១១-ចូខេម ហ្វ៊ូតវែរ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **សេង រ៉ូចហ៊ុន**

អាជ្ញាកណ្តាលក្នុងបញ្ជីភាគីកម្មករនិយោជិត : **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាល : **ញាន សុមុន្និន្ទ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ចូខេម ហ្វ៊ូតវែរ**

អាសយដ្ឋាន : ផ្លូវលេខ ២០០៤ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧៦៦ ៤២៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមផ្តល់ព័ត៌មានលើកទី១ :

| | |
|---|---|
| ១- លោក លី ឆេង | ទីប្រឹក្សាក្រុមហ៊ុន |
| ២- លោក David Jen Jen | រដ្ឋបាល |
| ៣- លោក Vincent | រដ្ឋបាល |
| ៤- លោក លី គីមអាន | ជំនួយការរដ្ឋបាល |
| ៥- លោក លូ គីមហុង | បកប្រែ |
| ៦- កញ្ញា ហេង ស្រីមុំ | បកប្រែ |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org Website: www.arbitrationcouncil.org

តំណាងភាគីនិយោជកចូលរួមផ្ដល់ព័ត៌មានលើកទី២ :

| | |
|---|---|
| ១- លោក លី ឆេង | ទីប្រឹក្សាក្រុមហ៊ុន |
| ២- លោក David Jen Jen | រដ្ឋបាល |
| ៣- លោក លី គីមអាន | ជំនួយការរដ្ឋបាល |
| ៤- កញ្ញា ហេង ស្រីមុំម | បកប្រែ |

២- **ភាគីកម្មករនិយោជិត**

យោងតាមកំណត់ហេតុរបស់ក្រសួងការងារ

ឈ្មោះ : - **សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ**

- **សហជីពសម្លេងយុវជនខ្មែរ នៃក្រុមហ៊ុន ចូខេម ហ្វ៊ិតវែរ**

អាសយដ្ឋាន : ផ្លូវលេខ ២០០៤ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៧១៣ ០៦៥ ទូរសារ : គ្មាន

យោងតាមឯកសារពាក្យប្ដឹងទាមទាររបស់កម្មករ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១១ ដែលមានភ្ជាប់ជាមួយសំណុំឯកសារនៃកំណត់ហេតុមិនសះជា

ឈ្មោះ : សន ចាន់សល់, ហ៊ឹម ឡុង, ជុន សេដ្ឋា, ចាន់ សុផារ័ត្ន, ជា សារុំ, នង ធីតា និង និត ស៊ីណេ

តំណាងកម្មករនិយោជិតចូលរួមផ្ដល់ព័ត៌មានលើកទី១ : **អវត្តមាន**

តំណាងកម្មករនិយោជិតចូលរួមផ្ដល់ព័ត៌មានលើកទី២ : **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនទទួលយកគណៈកម្មាធិការសហជីពសម្លេងយុវជនខ្មែរ ឈ្មោះ ជុន សេដ្ឋា និង ឈ្មោះ ចាន់ សុផារ័ត្ន ឱ្យចូលធ្វើការវិញ។

២- សុំឱ្យក្រុមហ៊ុនឈប់ប្រើកម្លាំងប្រដាប់អាវុធដើរគំរាមកំហែងកម្មករ និងសុំឱ្យអាជ្ញាធរមានសមត្ថកិច្ចបើកការស្រាវជ្រាវអំពីករណីនេះ។

៣- នៅពេលក្រុមហ៊ុនតម្រូវឱ្យកម្មករធ្វើការងារថែមម៉ោង ពីម៉ោង ១៩:០០ នាទី ដល់ម៉ោង ២១:០០ សុំឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ថ្លៃបាយមួយម៉ោង ១០០០ រៀល។

៤- សុំឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូននៅក្នុងក្រុមហ៊ុន។

៥- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់ចេញម៉ោង ១៦:០០ នៅរៀងរាល់ថ្ងៃសៅរ៍។

៦- សុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់រង្វាន់អតីតភាពការងារជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ (រំលឹកសង)។

៧- សុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតឱ្យបានមុនម៉ោង ១៦:០០ នៅថ្ងៃបើកប្រាក់ឈ្នួល ។

៨- សុំឱ្យក្រុមហ៊ុនកុំធ្វើការរើសអើងចំពោះថ្នាក់ដឹកនាំសហជីព គណៈកម្មាធិការ និងកម្មករដែលចូលជាសមាជិកសហជីពសម្លេងយុវជនខ្មែរ ។

៩- សុំឱ្យក្រុមហ៊ុនចាត់វិធានការដកអ្នកគ្រប់គ្រង ឈ្មោះ ដេវីត ចេញជាបន្ទាន់ ព្រោះបុគ្គលនេះ មានអាកប្បកិរិយាច្រងេងច្រងាង និងមានចារិកមើលងាយមើលថោកមកលើកម្មករនិយោជិត ។

១០- សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានពីសមាជិកសហជីពសម្លេងយុវជនខ្មែរ ជូនសហជីពសម្លេងយុវជនខ្មែរ ។

ដោយឡែកភាគីកម្មករនិយោជិតអវត្តមានដោយគ្មានមូលហេតុមកបញ្ជាក់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៥៧៣ កប/អក/វក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ :**

- **លើកទី១ :** ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១ (វេលាម៉ោង ៨:៣០ នាទី ព្រឹក) ។
- **លើកទី២ :** ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ (វេលាម៉ោង ២:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរស័ព្ទរបស់កម្មករនិយោជិត ស្តីពីការធ្វើកូដកម្មទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួន។ បន្ទាប់ពីបានទទួលបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារដល់ទីតាំងក្រុមហ៊ុន ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ១០ ចំណុច លើការទាមទារចំនួន ១០ ចំណុច ដោយសារភាគីកម្មករនិយោជិតមិនបានមកចូលរួមដោះស្រាយតាមកាលកំណត់របស់នាយកដ្ឋានវិវាទការងារឡើយ។ ចំណុចមិនសះជាចំនួន ១០ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។

នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១១ ភាគីនិយោជកបានអញ្ជើញមកជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីនិយោជកតាមការកំណត់។ ចំណែកឯ ភាគីកម្មករនិយោជិតខកខានមិនបានមកជ្រើសរើសអាជ្ញាកណ្តាលតាមការកំណត់នោះទេ ដោយមិនបានបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ដូចនេះ ការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីកម្មករនិយោជិតត្រូវបានធ្វើឡើងដោយប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ជាលទ្ធផលនៃការចាប់ឆ្នោតអាជ្ញាកណ្តាល ស៊ិន គឹមស៊ាន ត្រូវបានជ្រើសរើសជាអាជ្ញាកណ្តាលពីបញ្ជីកម្មករនិយោជិត។ ប្រធានក្រុមអាជ្ញាកណ្តាលក៏ត្រូវបានជ្រើសរើសតាមរយៈការចាប់ឆ្នោត នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ផងដែរ។

នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ដដែលនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានទទួលលិខិតរបស់នាយកក្រុមហ៊ុន ចូខេម ហ្វិតវែរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាលស្តីពីសុំចេញបញ្ជាឱ្យកម្មករនិយោជិត ដែលចូលរួមធ្វើកូដកម្មទាំងអស់ផ្អាកធ្វើកូដកម្ម តាមរយៈលិខិតចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១។ បន្ទាប់ពីទទួលដំណឹងនេះមក ក្រុមអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាមួយលេខ ០០៨/១១ កបអ. ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។ នៅក្នុងសេចក្តីបញ្ជានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាឱ្យកម្មករនិយោជិតទាំងអស់ផ្អាកការធ្វើកូដកម្ម និងចូលធ្វើការវិញចាប់ពី ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១ តទៅ រង់ចាំនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ចប់ លើកលែងតែកម្មករនិយោជិត ឈ្មោះ ជុន សេដ្ឋា និងឈ្មោះ សុផារត្ន័ ដោយសារកម្មករនិយោជិតទាំងពីររូបនេះ ពាក់ព័ន្ធនឹងបណ្តឹងទាមទារឱ្យចូលធ្វើការវិញ។

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលដំណឹងពីក្រុមហ៊ុនថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម មិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ដូចនេះ នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឱ្យលេខាធិការដ្ឋានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកចូលរួមប្រជុំ ដើម្បីសាកសួរព័ត៌មានស្តីពីការធ្វើកូដកម្ម នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅក្នុងពេលប្រជុំនោះ ភាគីនិយោជកមានវត្តមានតាមការអញ្ជើញ រីឯភាគីសហជីពកម្មករនិយោជិតអវត្តមាន។ នៅពេលដែលលេខា-

ធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការទំនាក់ទំនងទៅកាន់មន្ត្រីសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ឈ្មោះ អន សាខន មន្ត្រីរូបនោះបានបញ្ជាក់ថា កម្មករនិយោជិតបន្តធ្វើកូដកម្មនៅឡើយ។ នៅក្នុងពេលធ្វើការប្រជុំមុនសវនាការលើកទីមួយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសាកសួរព័ត៌មាន ពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងផ្អែកតាមព័ត៌មានទទួលបានពីភាគីនិយោជក ដែលមានតំណាងមកចូលរួមក្នុងកិច្ចប្រជុំសាកសួរព័ត៌មានមុនពេលសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិនិត្យឃើញថា សហព័ន្ធសហជីពសម្លេងយុវជនខ្មែរមិនទទួលស្គាល់ថា ខ្លួនមានការពាក់ព័ន្ធក្នុងសំណុំរឿងនេះទេ ដោយផ្ដល់ហេតុផលថា កម្មករនិយោជិតពាក់ព័ន្ធក្នុងសំណុំរឿងនេះ ធ្វើការក្នុងរោងចក្រ ហ្វូរអេវ័រ គឺមិនមែនក្នុងរោងចក្រ ចូខេម ទេ។ ភាគីនិយោជកក៏បានបញ្ជាក់ដែរថា សហជីពសម្លេងយុវជនខ្មែរនៃក្រុមហ៊ុន ចូខេម ហ្វ៊ូតវ៉ែរ មិនទាន់មាន បញ្ជិកានៅឡើយទេ។ លើសពីនេះ ភាគីនិយោជកក៏បានអះអាង និងយកភស្តុតាងបង្ហាញក្រុមប្រឹក្សាអាជ្ញាកណ្ដាលថា ក្នុងចំណោមកម្មករនិយោជិតដែលមានឈ្មោះ និងស្នាមមេដៃក្នុងពាក្យប្ដឹងទាមទារ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១១ គឺមានទាំងកម្មករនិយោជិត ដែលបំរើការក្នុងរោងចក្រ ចូខេម និងកម្មករនិយោជិត ដែលបំរើការក្នុងរោងចក្រ ហ្វូរអេវ័រ។ ដោយគ្មានឯកសារបញ្ជាក់ពីការអះអាងរបស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ក៏ដូចជាអំពីការផ្ទេរសិទ្ធិណាមួយរវាងកម្មករនិយោជិតដើមបណ្ដឹង ដែលមានឈ្មោះ សន ចាន់សល់, ហ៊ឹម ឡុង, ជុន សេដ្ឋា, ចាន់ សុផារ័ត្ន, ជា សារុំ, នង ធីតា និង និត ស៊ីណេ ជូនសហព័ន្ធសហជីពសម្លេងយុវជនខ្មែរ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការឆ្លើយបញ្ជាក់របស់មន្ត្រីសហព័ន្ធមិនទាន់អាចយកជាការបានឡើយ។

ដោយមានការសង្ស័យពីភាពជាតំណាង ក៏ដូចជាការពាក់ព័ន្ធរបស់សហព័ន្ធសហជីពសម្លេងយុវជនខ្មែរ និងអំពីអត្ថិភាពនៃសហជីពសម្លេងយុវជនខ្មែរនៃក្រុមហ៊ុន ចូខេម ហ្វ៊ូតវ៉ែរ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានសំណូមពរឱ្យលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើលិខិតជូនដំណឹងដល់គូភាគីជាថ្មីម្ដងទៀតអំពីការអញ្ជើញឱ្យមកចូលរួមកិច្ចប្រជុំមុនពេលសវនាការលើកទី២។ ឆ្លើយតបចំពោះសំណូមពរនេះ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើលិខិតកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតពាក់ព័ន្ធឈ្មោះ សន ចាន់សល់, ហ៊ឹម ឡុង, ជុន សេដ្ឋា, ចាន់ សុផារ័ត្ន, ជា សារុំ, នង ធិតា និង និត ស៊ីណេ ដែលជាម្ចាស់បណ្ដឹង ដោយបានផ្ដិតមេដៃលើពាក្យប្ដឹងទាមទារ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១១ មកចូលរួមប្រជុំ ដើម្បីសាកសួរព័ត៌មានម្ដងទៀត នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ០២:០០ នាទី រសៀល នៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចាត់ចែងឱ្យមានការបិទប្រកាសលិខិតអញ្ជើញនោះនៅមុខក្លោងទ្វាររោងចក្រ តាមការណែនាំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ។

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ០២:០០ នាទី រសៀល ក្នុងកិច្ចប្រជុំដើម្បីសាកសួរព័ត៌មានលើកទី២នោះ មានតែភាគីនិយោជកម្ខាងដដែល ដែលមានវត្តមានចូលរួមតាមការអញ្ជើញ រីឯភាគីតំណាងកម្មករនិយោជិតដែលមានឈ្មោះ សន ចាន់សល់, ហ៊ឹម ឡុង, ជុន សេដ្ឋា, ចាន់ សុផារ័ត្ន, ជា សារុំ, នង

ធីតា និង និត ស៊ីណេ ដែលជាម្ចាស់បណ្តឹងនេះផង គ្មានវត្តមានក្នុងកិច្ចប្រជុំនោះឡើយ។ តាមការសាកសួររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីនិយោជកបានបញ្ជាក់ថា រហូតមកដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ នេះ កម្មករនិយោជិតមួយចំនួន រួមទាំងកម្មករនិយោជិតម្ចាស់បណ្តឹងខ្លះ នៅតែបន្តធ្វើកូដកម្មនៅខាងមុខរោងចក្រ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតរបស់នាយកក្រុមហ៊ុន ចូខេម ហ្វូតវែរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំចេញបញ្ជាឱ្យកម្មករដែលចូលរួមធ្វើកូដកម្មទាំងអស់ ផ្អាកធ្វើកូដកម្ម ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១។

២- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ចូខេម ហ្វូតវែរ លេខ ៥៧៣ កប/អក/វក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ចូខេម ហ្វូតវែរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល គោរពជូន លោកប្រធានសហជីពសម្លេងយុវជនខ្មែរ នៃក្រុមហ៊ុន ចូខេម ហ្វូតវែរ ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល លេខ ៣៥៨ កប/អក/វក/ លកអ. ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីពកម្មករនិយោជិត និងការចាប់ឆ្នោតជ្រើសរើសប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។

THE ARBITRATION COUNCIL

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មានលើកទី១ លេខ ៣៧០ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មានលើកទី១ លេខ ៣៧១ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មានលើកទី២ លេខ ៣៧៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១។

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល រកឃើញថា :**

គ្មានការបង្ហាញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ព្រោះសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន ដោយសារភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងមិនគោរពតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឱ្យផ្អាកការធ្វើកូដកម្ម និងឱ្យចូលធ្វើការវិញទេ ហើយម្យ៉ាងទៀត គ្មានតំណាងកម្មករនិយោជិតដែលពាក់ព័ន្ធក្នុងសំណុំរឿងនេះណាម្នាក់បានមកចូលរួមក្នុងកិច្ចប្រជុំសាកសួរព័ត៌មាន មុនពេលសវនាការឡើយ។

**ហេតុផលនៃសេចក្តីសម្រេច :**

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា :

*"ក្នុងកំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម។"*

បន្ថែមលើនេះទៀត នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬ និយោជកធ្វើការឡុកអៅ។

នៅក្នុងសំណុំរឿង លេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងដល់ភាគីក្នុងសំណុំរឿងនោះ តាមរយៈលិខិត ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខណ្ឌទី៤ ដែលមានខ្លឹមសារថា *"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការ*

*របស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួម ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម"* ។

នៅក្នុងសំណុំរឿង ៧៧/០៥-ហ្វ្រង់កូ នីតធីង ហ្វាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា *" នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។ "*

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម និងសំណុំរឿងលេខ ៣៤/០៦-ហ្គោល ហ្វេម ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះចោល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ (សូមមើលបន្ថែមក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៩៧/០៧-ស៊ូត វ៉ៃ ។)

នៅក្នុងសំណុំរឿងនេះ និយោជកបានអះអាងថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម រហូតដល់នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ ទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញសេចក្តីបញ្ជាឱ្យកម្មករនិយោជិតបញ្ឈប់នូវសកម្មភាពនេះក៏ដោយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការព្យាយាមកោះហៅកម្មករនិយោជិតមកធ្វើការសាកសួរព័ត៌មានពីបញ្ហាកូដកម្មនេះចំនួនពីរដង ប៉ុន្តែ ភាគីកម្មករនិយោជិតខកខានមិនបានចូលរួមការជួបប្រជុំដើម្បីសាកសួរព័ត៌មានម្តងណាឡើយ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានភស្តុតាងផ្ទុយណាមួយដែលបញ្ជាក់ថា កម្មករនិយោជិតបានបញ្ឈប់នូវការធ្វើកូដកម្ម បន្ទាប់ពីមានការបញ្ជាពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតដែលជាម្ចាស់បណ្តឹងមិនបានចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយក៏មិនបានមកបង្ហាញពីចេតនាពិតប្រាកដណាមួយថា ពួកគាត់មានបំណងយកវិវាទការងារនេះមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ព្រោះភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ហើយមិនគោរពតាមបញ្ជា និងការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ហេតុដូច្នេះ យោងតាមបញ្ញត្តិនៃច្បាប់ការងារ ព្រមទាំងជាការបង្ហាញនូវការគាំទ្រចំពោះការបកស្រាយច្បាប់ក្នុងសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗទាក់ទងនឹងការមិនគោរពបញ្ជា និង ការមិនចូលរួមការប្រជុំតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏សម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលទេ ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ :

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

## សម្រេច

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ៦៣/១១-ចូខេម ហ្វ៊ុតវែរ។

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **សេង ទូចហ៊ុន**

ហត្ថលេខា : ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **ស៊ីន គឹមសាន**

ហត្ថលេខា : ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ញាន សុមុន្និន្ទ**

ហត្ថលេខា : ------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL